លេខៈ ៤១ សតកង                                                                 រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០០៨

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុៈ** សំណើសុំបញ្ចុះតម្លៃប្រេងឥន្ធនៈ ឱ្យមានតម្លៃតុល្យភាពទៅនឹងតម្លៃប្រេងឥន្ធនៈនៅទីផ្សារអន្តរជាតិ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយស សូមជម្រាបសម្តេចអគ្គមហាសេនាបតីតេជោជ្រាបថាៈ មកដល់ថ្ងៃនេះ តម្លៃប្រេងឥន្ធនៈនៅទីផ្សារអន្តរជាតិមានការធ្លាក់ចុះតម្លៃមកត្រឹម **១០៩ដុល្លារ** ក្នុងមួយធុង ដែលមានចំណុះ**២០០** លីត្រ ។

ចំពោះតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារប្រទេសកម្ពុជា នៅតែមានតម្លៃខ្ពស់ **៥ ៤០០រៀល** ក្នុងមួយលីត្រ បើធៀបទៅនឹងតម្លៃទីផ្សារអន្តរជាតិ គឺមានតម្លៃអតុល្យភាពគ្នាខ្លាំងណាស់ ។ ក្នុងខណៈដែលទីផ្សារប្រេងឥន្ធនៈអន្តរជាតិមានការធ្លាក់ចុះ ប្រមាណជា**៤០ដុល្លារ**ក្នុងមួយធុង តម្លៃប្រេងឥន្ធនៈនៅកម្ពុជាត្រូវមានតម្លៃត្រឹម៤ ០០០**រៀល** ក្នុងមួយលីត្រ ទើបមានតុល្យភាពគ្នា ។

នៅពេលតម្លៃអតិផរណាទីផ្សារហក់ឡើងខ្ពស់ រាជរដ្ឋាភិបាលកម្ពុជាតែងតែអះអាងថា បណ្តាមកពីទីផ្សារអន្តរជាតិមានតម្លៃខ្ពស់ដែរ ។ ប៉ុន្តែបច្ចុប្បន្ននេះ តម្លៃទីផ្សារអន្តរជាតិមានការធ្លាក់ចុះ ដោយឡែកទីផ្សារកម្ពុជានៅតែមានតម្លៃខ្ពស់ដដែល ។ បញ្ហានេះប្រជារាស្ត្រ និង លោកគ្រូ អ្នកគ្រូ បាននឹងកំពុងប្រឈមមុខយ៉ាងខ្លាំងចំពោះជីវភាពរស់នៅប្រចាំថ្ងៃ ហើយរាជរដ្ឋាភិបាលត្រូវដោះស្រាយបញ្ហាតម្លៃប្រេងឥន្ធនៈ ឱ្យសមមូលទៅនឹងតម្លៃប្រេងឥន្ធនៈអន្តរជាតិ ។

អាស្រ័យហេតុដូចបានគោរព និង ជម្រាបជូនខាងលើ ខ្ញុំសង្ឃឹមថា សម្តេចអគ្គមហាសេនាបតីតេជោ នឹងដោះស្រាយតម្លៃអតិផរណាទីផ្សារនៅកម្ពុជា ឱ្យសមមូលទៅនឹងតម្លៃទីផ្សារអន្តរជាតិ ជាក់ជាមិនខានឡើយ ។

សូមសម្តេចអគ្គមហាសេនាបតីតេជោ ទទួលការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ប្រធាន**

**[ហត្ថលេខា]**

<u>ចម្លងជូន និង ជូនៈ</u>

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា - ព្រឹទ្ធសភា

-ក្រសួងពាក់ព័ន្ធ

-ស្ថានទូតនានាប្រចាំនៅកម្ពុជា

-អង្គការនានាប្រចាំនៅកម្ពុជា

-ឯកសារ-កាលប្បវត្តិ